ក្រសួងមុខងារសាធារណៈ

MINISTRY OF CIVIL SERVICE

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការដាក់ឱ្យដំណើរការការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ សម្រាប់ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៣៨៤/២៤ មស.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឱ្យដំណើរការការវាយតម្លៃនិងការទទួលស្គាល់ អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យភាពសាធារណៈ
- យោងតាមការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

កំណត់យកវិទ្យាល័យ និងសាលាមត្តេយ្យសិក្សា(មត្តេយ្យសិក្សាធនធាននិងមត្តេយ្យសិក្សាដាច់ដោយឡែក) ជាអង្គភាពផ្ដល់សេវាសាធារណៈ សម្រាប់ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំសម្រាប់ឆ្នាំ២០២៤។

**ប្រការ២ .-**

ការវាយតម្លៃនិងការទទួលស្គាល់វិទ្យាល័យ និងសាលាមត្តេយ្យសិក្សាគំរូ ត្រូវអនុវត្តអនុលោមតាមអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងត្រូវអនុវត្តផ្អែកលើតារាងលក្ខណៈវិនិច្ឆ័យដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងវិទ្យាល័យនិងសាលាមត្តេយ្យសិក្សានៃក្រសួងអប់រំ យុវជន និងកីឡាទូទាំងប្រទេស ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ២០២៤

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| --- | --- | --- |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រសួងមុខងារសាធារណៈ |
| អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន | ហ៊ុន ម៉ានី |

**កន្លែងទទួល:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួងលេខ ៣៨៤/២៤ មស.គចជ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការដាក់ឱ្យដំណើរការ ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

## តារាងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនិងការទទួលស្គាល់វិទ្យាល័យគំរូ
## (ពិន្ទុសរុប ៨៣៥)

| លក្ខណៈវិនិច្ឆ័យគោល | លក្ខណៈវិនិច្ឆ័យរង | ចំណុចលម្អិត | ពិន្ទុ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ០ | ១ | ២ | ៣ | ៤ | ៥ |
| ១. ស្តង់ដាសេវាសាធារណៈ (១១៥ពិន្ទុ) | ១.១ គុណភាពព័ត៌មាន (៤០ពិន្ទុ) | ១.១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ មានរក្សាទុកបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់អ្នកប្រើសេវាអាចពិនិត្យផ្ទៀងផ្ទាត់អំពីសេវា | | | | | | |
| | | ➢ បានរៀបចំស្តង់ដាផ្តល់សេវារដ្ឋបាល និងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន | | | | | | |
| | | ១.១.២ ការផ្សព្វផ្សាយព័ត៌មានអំពីសេវា (២០ពិន្ទុ) | | | | | | |
| | | ➢ បានផ្សព្វផ្សាយផែនការអភិវឌ្ឍរបស់សាលារៀន | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលសេវាសាលារៀន | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានអំពីម៉ោងពេលបំពេញការងារ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានអំពីមធ្យោបាយទំនាក់ទំនងរបស់សាលារៀន | | | | | | |
| | | ១.១.៣ មធ្យោបាយផ្សព្វផ្សាយព័ត៌មានអំពីសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធមិនមែនអេឡិចត្រូនិក (ឧគ្ឃោសនសព្ទ កម្រងព័ត៌មានស្តីពីសេវាសាធារណៈ ព្រឹត្តិបត្រព័ត៌មាន សារព័ត៌មាន ផ្សព្វផ្សាយតាមសហគមន៍ ខិតប័ណ្ណ និងការផ្សាយនៅនឹងកន្លែង) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធឌីជីថល (ដូចជា Facebook, Telegram, Tweeter...) | | | | | | |
| | ១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា (៣៥ពិន្ទុ) | ១.២.១ ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ (១៥ពិន្ទុ) | | | | | | |
| | | ➢ មានហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសាលារៀនប្រកបដោយភាពងាយស្រួលក្នុងការស្វែងរកនិងទទួលយកសេវា | | | | | | |
| | | ➢ មានបិទបង្ហាញប្លង់ទីតាំងសាលារៀន និងស្លាកសញ្ញាប្រាប់ពីឈ្មោះអង្គភាពទទួលបន្ទុកការងារនីមួយៗច្បាស់លាស់ | | | | | | |
| | | ➢ មានចំណតសម្រាប់ចតយានជំនិះ ព្រមទាំងមានការបែងចែករវាងចំណតសម្រាប់បុគ្គលិកអប់រំ និងសិស្សប្រកបដោយសណ្តាប់ធ្នាប់ និងមានអនាម័យស្អាតជាប្រចាំ | | | | | | |
| | | ១.២.២ ទីតាំងផ្តល់សេវាប្រកបដោយផាសុកភាព (១០ពិន្ទុ) | | | | | | |
| | | ➢ បានរៀបចំបរិស្ថាននៅក្នុងថ្នាក់រៀនប្រកបដោយផាសុកភាព | | | | | | |
| | | ➢ បានរៀបចំបរិស្ថាននៅក្នុងបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់ផ្តល់សេវាផ្សេងៗប្រកបដោយសុវត្ថិភាពនិងផាសុកភាព | | | | | | |
| | | ១.២.៣ បែបបទនិងលក្ខខណ្ឌនៃការទទួលយកសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ បានសិក្សានិងរៀបចំឯកសារតម្រូវសម្រាប់ទទួលសេវាមានចំនួនតិច និងទម្រង់នៃពាក្យស្នើសុំសេវាមានលក្ខណៈងាយយល់និងងាយបំពេញ | | | | | | |
| | | ➢ នីតិវិធីនៃការទទួលយកសេវាមានលក្ខណៈសាមញ្ញ និងឆាប់រហ័ស | | | | | | |
| | ១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (២៥ពិន្ទុ) | ១.៣.១ ការរៀបចំបដិសណ្ឋារកិច្ច (២០ពិន្ទុ) | | | | | | |
| | | ➢ បានរៀបចំឱ្យបុគ្គលិកអប់រំមានឯកសណ្ឋានឬសម្លៀកបំពាក់សមរម្យ និងពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ បានរៀបចំឱ្យសិស្សមានឯកសណ្ឋាន(សម្លៀកបំពាក់សមរម្យ និង មានស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងសាលារៀន) និង មានសីលធម៌/សុជីវធម៌ និងភាពរួសរាយរាក់ទាក់ | | | | | | |
| | | ➢ ការរៀបចំឱ្យមានទីកន្លែង(ផ្ទៃក តុ ឬទីតាំង)សម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវារបស់សាលារៀន | | | | | | |
| | | ➢ បុគ្គលិកអប់រំមានភាពរួសរាយរាក់ទាក់ និងមានសីលធម៌/សុជីវធម៌ | | | | | | |
| | | ១.៣.២ យន្តការសម្របសម្រួល (៥ពិន្ទុ) | | | | | | |
| | | ➢ មានការយកចិត្តទុកដាក់ និងសម្របសម្រួលដោះស្រាយការលំបាករបស់អ្នកប្រើសេវាតាមទិដ្ឋភាពជាក់ស្តែង | | | | | | |
| | ១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ (១៥ពិន្ទុ) | ១.៤.១ ការផ្តល់សេវាតាមគោលការណ៍កំណត់ (១០ពិន្ទុ) | | | | | | |
| | | ➢ បានផ្តល់សេវាស្របតាមការកំណត់ (ដូចជាតម្លៃ រយៈពេល...) | | | | | | |
| | | ➢ សាលារៀនទទួលបានវិញ្ញាបនបត្រ/បណ្ណសរសើរ/លិខិតសរសើរពីការផ្តល់សេវា(ដៃគូអភិវឌ្ឍ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ថ្នាក់ជាតិ និង/ឬ អន្តរជាតិ) | | | | | | |
| | | ១.៤.២ សេវាផ្តល់មានអភិបាលកិច្ចល្អ (៥ពិន្ទុ) | | | | | | |
| | | ➢ បានផ្តល់សេវាប្រកបដោយសមធម៌ និងបរិយាបន្ន(ជួយដល់សិស្សដែលមានពិការភាព និងសិស្សក្រីក្រ ដោយមានជម្រាលបន្ទប់ស្នាក់នៅ ឧបករណ៍សម្ភារៈជំនួយសិស្សដែលមានពិការភាព និងអាហារូបករណ៍...) | | | | | | |
| **២. ស្តង់ដាឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ** (២៩០ពិន្ទុ) | ២.១ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន (១៧០ពិន្ទុ) | ២.១.១ ភាពជាអ្នកដឹកនាំសាលារៀន (២៥ពិន្ទុ) | | | | | | |
| | | ➢ មានចក្ខុវិស័យសាលារៀនឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ/គោលនយោបាយអប់រំ | | | | | | |
| | | ➢ មានបេសកកម្មឆ្លើយតបទៅចក្ខុវិស័យ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ គុណតម្លៃឬបាវចនារបស់សាលារៀន | | | | | | |
| | | ➢ ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកអប់រំបានស្របតាមកម្រិតជំនាញ កម្រិតវិជ្ជាជីវៈ និងនិយាម | | | | | | |
| | | ➢ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការគ្រប់គ្រងសាលារៀន | | | | | | |
| | | ២.១.២ ការរៀបចំផែនការ និងដំណើរការសាលារៀន (២៥ពិន្ទុ) | | | | | | |
| | | ➢ មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន(៥ឆ្នាំ) | | | | | | |
| | | ➢ មានផែនការប្រតិបត្តិប្រចាំឆ្នាំ ឬផែនការកែលម្អសាលារៀន | | | | | | |
| | | ➢ មានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារជាប្រចាំ | | | | | | |
| | | ➢ ស្វ័យវាយតម្លៃសាលារៀនប្រចាំឆ្នាំ ឆ្លុះបញ្ចាំងទៅនឹងផែនការប្រចាំឆ្នាំ | | | | | | |
| | | ➢ សមិទ្ធកម្មធៀបនឹងផែនការដែលបានកំណត់ | | | | | | |
| | | ២.១.៣ ការដឹកនាំការបង្រៀននិងរៀន (៥០ពិន្ទុ) | | | | | | |
| | | ➢ ដឹកនាំ និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សា និងការវាយតម្លៃការសិក្សាកម្រិតសាលារៀន | | | | | | |
| | | ➢ ដឹកនាំរៀបចំ និងអនុវត្តសកម្មភាពកម្មវិធីសិក្សាបន្ថែម | | | | | | |
| | | ➢ មានរបបប្រជុំក្រុមបច្ចេកទេសតាមមុខវិជ្ជា(យ៉ាងតិច ៧ដងក្នុង ១ឆ្នាំ) និងមានរបៀបវារៈច្បាស់លាស់តាមការណែនាំ/ការកំណត់ | | | | | | |
| | | ➢ មានផែនការ និងអនុវត្តអធិការកិច្ចផ្ទៃក្នុងលើការបង្រៀននិងរៀនជាប្រចាំ | | | | | | |
| | | ➢ មានកម្មវិធីណែនាំគ្រូបង្រៀនដែលទើបចេញមកបង្រៀនថ្មី | | | | | | |
| | | ➢ មានការលើកទឹកចិត្ត និងចេះធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែក | | | | | | |
| | | ➢ មានការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សជាប្រចាំ(ការធ្វើតេស្តស្តង់ដា) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានការផ្តល់និងទទួលព័ត៌មានត្រឡប់អំពីលទ្ធផលសិក្សារបស់សិស្ស(សៀវភៅតាមដានការសិក្សា តាមលិខិតអញ្ជើញ...) ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអ្នកពាក់ព័ន្ធជាប្រចាំ | | | | | | |
| | | ➢ រៀបចំឱ្យមានសម្ភារៈសិក្សា និងសម្ភារៈឧបទេសតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ | | | | | | |
| | | ➢ មានផែនការបង្រៀន វិធីសាស្ត្របង្រៀនថ្មីៗ និងកិច្ចតែងការបង្រៀនសម្របតាមសមត្ថភាពសិស្ស | | | | | | |
| | | ២.១.៤ ការធានាគណនេយ្យភាព (១០ពិន្ទុ) | | | | | | |
| | | ➢ ការគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធរាយការណ៍ | | | | | | |
| | | ➢ បិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាព | | | | | | |
| | | ២.១.៥ ការគ្រប់គ្រងប្រកបដោយសុចរិតភាព (២០ពិន្ទុ) | | | | | | |
| | | ➢ ការណែនាំនិងផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | | | | | | |
| | | ➢ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | | | | | | |
| | | ➢ ផ្តល់ដំបូន្មាន និងអប់រំណែនាំបទបញ្ជាផ្ទៃក្នុង វិន័យសាលា សីលធម៌ និងសុជីវធម៌ដល់សិស្សជាប្រចាំ | | | | | | |
| | | ➢ មានគណនេយ្យភាព ភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ក្នុងការវិនិច្ឆ័យការសិក្សារបស់សិស្ស | | | | | | |
| | | ២.១.៦ លទ្ធផលនៃការសិក្សា (៤០ពិន្ទុ) | | | | | | |
| | | ➢ អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ | | | | | | |
| | | ➢ អត្រាសិស្សចុះឈ្មោះចូលរៀនខ្ពស់ជាង ឬស្មើថ្នាក់ជាតិ | | | | | | |
| | | ➢ អត្រាសិស្សឡើងថ្នាក់ខ្ពស់ជាង ឬស្មើថ្នាក់ជាតិ | | | | | | |
| | | ➢ សិស្សពូកែថ្នាក់រាជធានី ខេត្ត/ថ្នាក់ជាតិ/អន្តរជាតិ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិស្មើ ឬ ខ្ពស់ជាងថ្នាក់ជាតិ | | | | | | |
| | | ➢ ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និទ្ទេស A, B និងC ធៀបនឹងថ្នាក់ជាតិ | | | | | | |
| | | ➢ អត្រាសិស្សត្រួតថ្នាក់ទាបជាង ឬស្មើថ្នាក់ជាតិ | | | | | | |
| | | ➢ សិស្សមានសមត្ថភាពស្របតាមកម្រិតថ្នាក់(ផ្អែកលើតេស្តស្តង់ដា) | | | | | | |
| | ២.២ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាធានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន (៤០ពិន្ទុ) | ២.២.១ ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពធានាដល់ការបង្រៀននិងរៀនប្រកបដោយគុណភាព (៤០ពិន្ទុ) | | | | | | |
| | | ➢ មានកម្មវិធី និងបន្ទប់សម្រាប់បង្រៀនកុំព្យូទ័រ | | | | | | |
| | | ➢ មានកម្មវិធី និងបន្ទប់សម្រាប់បង្រៀនភាសាបរទេស | | | | | | |
| | | ➢ មានកម្មវិធី និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ | | | | | | |
| | | ➢ មានបណ្ណាល័យ | | | | | | |
| | | ➢ មានបន្ទប់សម្រាប់គ្រូបង្រៀនធ្វើការ ប្រជុំ និងស្រាវជ្រាវ | | | | | | |
| | | ➢ មានបន្ទប់រោងជាងនិងគេហវិទ្យា ឬបន្ទប់សិល្បៈ | | | | | | |
| | | ➢ មានសម្ភារៈបច្ចេកវិទ្យានិងឌីជីថលសម្រាប់គាំទ្រការបង្រៀននិងរៀន | | | | | | |
| | | ➢ មានការផ្តល់អាហារូបករណ៍ និងសេវានានា ដើម្បីធានាសមភាព សមធម៌ និងបរិយាបន្ន | | | | | | |
| | ២.៣ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈបុគ្គលិកអប់រំ (៨០ពិន្ទុ) | ២.៣.១ ចំណេះដឹង និងសមត្ថភាពជំនាញរបស់បុគ្គលិកអប់រំ (៥៥ពិន្ទុ) | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំមានគុណវុឌ្ឍិចាប់ពីបរិញ្ញាបត្រឡើងទៅ | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម | | | | | | |
| | | ➢ ភាគរយនៃបុគ្គលិកអប់រំមានការយល់ដឹងគោលនយោបាយអប់រំ | | | | | | |
| | | ➢ ភាគរយនៃការប្រើប្រាស់កម្មវិធីសិក្សាតាមកម្រិតថ្នាក់របស់បុគ្គលិកអប់រំ | | | | | | |
| | | ➢ ភាគរយនៃគ្រូបង្រៀន បង្រៀនបានត្រឹមត្រូវតាមមុខវិជ្ជាឯកទេស និងតាមកម្រិតថ្នាក់ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ ភាគរយបុគ្គលិកអប់រំមានចំណេះដឹង និងប្រើបច្ចេកវិទ្យាព័ត៌មាន បម្រើឱ្យការងាររដ្ឋបាល និងការងារបច្ចេកទេស | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំចេះភាសាបរទេស | | | | | | |
| | | ➢ ភាគរយនៃបុគ្គលិកអប់រំមានបទពិសោធន៍ការងារចាប់ពី៥ឆ្នាំឡើងទៅ | | | | | | |
| | | ➢ ភាគរយនៃបុគ្គលិកអប់រំដែលប្រើប្រាស់ទិន្នន័យជាមូលដ្ឋានក្នុងការអនុវត្តការងារ | | | | | | |
| | | ➢ ភាគរយការបង្រៀនថ្នាក់និទស្សន៍ | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំដែលបានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ | | | | | | |
| | | ២.៣.២ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់គ្រូបង្រៀន (២៥ពិន្ទុ) | | | | | | |
| | | ➢ គ្រូបង្រៀនវិនិច្ឆ័យលទ្ធផលការសិក្សារបស់សិស្សបានត្រឹមត្រូវ និងតម្លាភាព | | | | | | |
| | | ➢ មានសៀវភៅរដ្ឋបាលថ្នាក់រៀន | | | | | | |
| | | ➢ មានការតាមដាន និងវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ | | | | | | |
| | | ➢ បង្កើត និងជំរុញសកម្មភាពក្លឹបសិក្សា | | | | | | |
| | | ➢ បណ្តុះស្មារតីគ្រូនិងសិស្សឱ្យចេះសិក្សាពេញមួយជីវិត | | | | | | |
| **៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព** (៩៥ពិន្ទុ) | ៣.១ ភាពជឿទុកចិត្តនៃថវិកា (៣៥ពិន្ទុ) | ៣.១.១ ការរៀបចំផែនការថវិកា (១០ពិន្ទុ) | | | | | | |
| | | ➢ ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) រំកិល (Y+1, Y+2, Y+3) | | | | | | |
| | | ➢ ផែនការថវិកាប្រចាំឆ្នាំ (Y+1) | | | | | | |
| | | ៣.១.២ ការអនុវត្តថវិកា (១០ពិន្ទុ) | | | | | | |
| | | ➢ ការអនុវត្តថវិកាស្របតាមការគ្រោងទុក | | | | | | |
| | | ➢ ការរៀបចំតារាងតម្លាភាពថវិកា និងគណនេយ្យភាពថវិកាឱ្យទៀងទាត់និងទាន់ពេល | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ៣.១.៣ ការកៀរគរថវិកា/គ្រប់គ្រងថវិកាប្រកដោយតម្លាភាពនិងគណនេយ្យភាពសម្រាប់អភិវឌ្ឍសាលារៀន (១៥ពិន្ទុ) | | | | | | |
| | | ➢ ការរៀបចំសមាសភាពនិងមុខងារគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈស្របតាមគោលការណ៍កំណត់ | | | | | | |
| | | ➢ ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនប្រកបដោយគណនេយ្យភាព និងប្រសិទ្ធភាព | | | | | | |
| | | ➢ ការកៀរគរថវិកាពីប្រភពស្របច្បាប់ផ្សេងៗដើម្បីអភិវឌ្ឍសាលារៀន | | | | | | |
| | ៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ (៣៥ពិន្ទុ) | ៣.២.១ ដំណើរការនៃការកត់ត្រា (២០ពិន្ទុ) | | | | | | |
| | | ➢ មានបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារកត់ត្រាគ្រប់ប្រតិបត្តិការសាច់ប្រាក់ក្នុងគណនីធនាគាររបស់សាលារៀនជាប្រចាំ(គំរូលេខ៤) | | | | | | |
| | | ➢ មានបញ្ជីបេឡាសម្រាប់តាមដានស្ថានភាពចំណូលចំណាយ និងចំនួនសាច់ប្រាក់ ដែលនៅសល់ចុងថ្ងៃ និងចុងខែ (គំរូលេខ៥) | | | | | | |
| | | ➢ កត់ត្រាកិច្ចបញ្ជិកាគណនេយ្យតាមកុំព្យូទ័រដោយប្រើ Ms.Excel ឬ កម្មវិធីដទៃទៀត | | | | | | |
| | | ➢ ការគ្រប់គ្រងឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ត្រូវបានរក្សាទុកតាមក្រូណូ តាមលំដាប់ និងមានភាពងាយស្រួលសម្រាប់ការប្រើប្រាស់ | | | | | | |
| | | ៣.២.២ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (១៥ពិន្ទុ) | | | | | | |
| | | ➢ ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋឱ្យបានទៀងទាត់និងជាប្រចាំ | | | | | | |
| | | ➢ ការធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវ | | | | | | |
| | | ➢ ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់សាលារៀន | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៣.៣ ការតាមដាន និងការត្រួតពិនិត្យ (២៥ពិន្ទុ) | ៣.៣.១ ប្រព័ន្ធរបាយការណ៍តាមដានជាប្រចាំ (២៥ពិន្ទុ) | | | | | | |
| | | ➢ មានរបាយការណ៍ចំណាយថវិកាប្រចាំខែ(ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំខែ និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល) | | | | | | |
| | | ➢ មានរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស(ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំត្រីមាស និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល) | | | | | | |
| | | ➢ មានរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសដែលឆ្លុះបញ្ចាំងពីព័ត៌មានសមិទ្ធកម្មគ្រប់ជ្រុងជ្រោយ | | | | | | |
| | | ➢ មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សាលារៀន និងរបាយការណ៍ | | | | | | |
| | | ➢ កាអនុវត្តតាមអនុសាសន៍ចុងក្រោយរបស់សវនកម្មផ្ទៃក្នុង ឬ អធិការកិច្ច | | | | | | |
| **៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព** (៨០ពិន្ទុ) | ៤.១ ការគ្រប់គ្រងធនធានមនុស្ស (៥៥ពិន្ទុ) | ៤.១.១ ការរៀបចំនិងអនុវត្តផែនការគ្រប់គ្រងធនធានមនុស្ស (៥ពិន្ទុ) | | | | | | |
| | | ➢ មានផែនការគ្រប់គ្រងធនធានមនុស្ស | | | | | | |
| | | ៤.១.២ ការគ្រប់គ្រងការវិវត្តន៍អាជីពរបស់បុគ្គលិកអប់រំ (១៥ពិន្ទុ) | | | | | | |
| | | ➢ ការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីផ្អែកតាមតម្រូវការពិតប្រាកដ និងអនុវត្តតាមបទដ្ឋានគតិយុត្តជាធរមាន | | | | | | |
| | | ➢ ការដំឡើងថ្នាក់និងឋានន្តរស័ក្តិត្រូវបានរៀបចំជាទៀងទាត់ | | | | | | |
| | | ➢ ការរៀបចំដាក់ឱ្យចូលនិវត្តន៍គោរពតាមគោលការណ៍កំណត់ | | | | | | |
| | | ៤.១.៣ ការគ្រប់គ្រងសមិទ្ធកម្ម (៣៥ពិន្ទុ) | | | | | | |
| | | ➢ ការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាព | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ ការរៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ (គណៈគ្រប់គ្រង ក្រុមបច្ចេកទេស គ្រូបង្រៀន និងបុគ្គលិកអប់រំ...) | | | | | | |
| | | ➢ ការរៀបចំលក្ខខណ្ឌការងារឬការបែងចែកភារកិច្ច(កិច្ចសន្យាការងារ) ដោយមានកំណត់សូចនាករច្បាស់លាស់ | | | | | | |
| | | ➢ ការគ្រប់គ្រងវត្តមានការបំពេញការងាររបស់បុគ្គលិកអប់រំជាទៀងទាត់ | | | | | | |
| | | ➢ មានការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្ត | | | | | | |
| | | ➢ មានការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | | | | |
| | | ➢ មានការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងអង្គភាព | | | | | | |
| | ៤.២ ការអភិវឌ្ឍធនធានមនុស្ស (២៥ពិន្ទុ) | ៤.២.១ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស (៥ពិន្ទុ) | | | | | | |
| | | ➢ មានការរៀបចំផែនការសិក្សាវិជ្ជាជីវៈ និងការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(ចូលរួមសិក្សារៀនសូត្រដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង ជំនាញ និងការអនុវត្តការងារឆ្លើយតបទៅនឹងតម្រូវការវិជ្ជាជីវៈ តម្រូវការរបស់សាលារៀន និងកំណែទម្រង់វិស័យអប់រំ) | | | | | | |
| | | ៤.២.២ ការអភិវឌ្ឍនិងការប្រើធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល(២០ពិន្ទុ) | | | | | | |
| | | ➢ គាំទ្រនិងលើកទឹកចិត្តមន្ត្រីឱ្យទទួលបានការបណ្តុះបណ្តាល | | | | | | |
| | | ➢ ប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីផ្តល់ការបណ្តុះបណ្តាល | | | | | | |
| | | ➢ មានការវាយតម្លៃលទ្ធផលទទួលបានពីការបណ្តុះបណ្តាល | | | | | | |
| | | ➢ មានការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំជាបន្តបន្ទាប់ | | | | | | |
| **៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព** (១១៥ពិន្ទុ) | ៥.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថានភាពស្អាត សុខភាព និងអនាម័យ (១៥ពិន្ទុ) | ៥.១.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត សុខភាព និងអនាម័យ (១៥ពិន្ទុ) | | | | | | |
| | | ➢ បានបញ្ចូលផែនការបរិស្ថាន ភាពស្អាត សុខភាព និងអនាម័យ ទៅក្នុងផែនការអភិវឌ្ឍសាលារៀន/កែលម្អសាលារៀន(តារាងផែនការប្រចាំឆ្នាំ) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ពិសេសគោលការណ៍៤R (យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក) ដល់បុគ្គលិកអប់រំនិងសិស្សានុសិស្ស | | | | | | |
| | | ➢ មានការបញ្ជ្រាបការយល់ដឹងពីសុខភាព អនាម័យ ដល់បុគ្គលិកអប់រំនិងសិស្សានុសិស្ស | | | | | | |
| | ៥.២ សោភ័ណភាពបរិស្ថានសាលារៀន (៤៥ពិន្ទុ) | ៥.២.១ ការអនុវត្តដើម្បីសុខភាព អនាម័យ ភាពស្អាត និងបៃតង នៅក្នុងសាលារៀន (៤៥ពិន្ទុ) | | | | | | |
| | | ➢ ទីធ្លាសាលារៀនមានសុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យ | | | | | | |
| | | ➢ ទីធ្លាសាលារៀនមានភាពបៃតង និងសោភ័ណភាព | | | | | | |
| | | ➢ មានសួនច្បារ ដើមឈើ និងសួនជីវៈចម្រុះប្រកបដោយសោភ័ណភាព និងសមស្របទៅនឹងទំហំនៃសាលារៀន | | | | | | |
| | | ➢ បន្ទប់រៀនមានសោភ័ណភាព និងមានការសម្អាតជាប្រចាំ | | | | | | |
| | | ➢ គ្មានការបំពុលបរិស្ថាន(ផ្សែង សំឡេង ក្លិន...) និងគ្មានផ្សែងបារីនៅក្នុងបរិវេណសាលារៀន | | | | | | |
| | | ➢ មានប្រអប់សង្គ្រោះបឋម និងបរិក្ខារជំនួយ | | | | | | |
| | | ➢ មានការបែងចែកបង្គន់សម្រាប់សិស្សស្រី សិស្សប្រុស អ្នកដែលមានពិការភាព និងបុគ្គលិកអប់រំ និងសមាមាត្រទៅនឹងចំនួនសិស្ស | | | | | | |
| | | ➢ បង្គន់ប្រកបដោយភាពស្អាត សុវត្ថិភាព អនាម័យ និងសោភ័ណភាព | | | | | | |
| | | ➢ មានកន្លែងលាងសម្អាតដៃប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងសោភ័ណភាព | | | | | | |
| | ៥.៣ ទីតាំងលេងកំសាន្ត និងគ្រប់គ្រងកាកសំណល់ (៣៥ពិន្ទុ) | ៥.៣.១ ទីលានលេងកំសាន្ត និង អប់រំកាយនិងកីឡា (១៥ពិន្ទុ) | | | | | | |
| | | ➢ មានកន្លែងសម្រាប់សិស្សានុសិស្ស និងបុគ្គលិកអប់រំស្វ័យសិក្សា និងលំហែកំសាន្ត ប្រកបដោយផាសុកភាព | | | | | | |
| | | ➢ មានទីលានលេងកីឡាស្របតាមនិយាម និងតាមកម្រិតភូមិសិក្សា | | | | | | |
| | | ➢ មានសម្ភារៈសម្រាប់លេងកីឡាគ្រប់គ្រាន់ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ៥.៣.២ ការគ្រប់គ្រងកាកសំណល់(ប្លាស្ទិក) និងប្រព័ន្ធលូ (២០ពិន្ទុ) | | | | | | |
| | | ➢ មានធុងសំរាមនិងបានញែកសំរាម(ជាពិសេសសំរាមប្លាស្ទិក) ព្រមទាំងមានការសម្អាតជាប្រចាំ | | | | | | |
| | | ➢ មានការអនុវត្តគោលការណ៍4R ក្នុងការគ្រប់គ្រងកាកសំណល់ (ប្លាស្ទិក) | | | | | | |
| | | ➢ មានទីតាំងសម្រាប់ស្តុកសំរាមប្រកបដោយសណ្តាប់ធ្នាប់ អនាម័យ និងសុវត្ថិភាព | | | | | | |
| | | ➢ មានប្រព័ន្ធគ្រប់គ្រងសំណល់រាវ និងមានការថែទាំជាប្រចាំ (ប្រព័ន្ធលូរំដោះទឹក និងទឹកសំអុយ) | | | | | | |
| | ៥.៤ ការប្រើប្រាស់ទឹកស្អាត និងអនាម័យចំណីអាហារដែលលក់ដូរក្នុងបរិវេណសាលារៀន (២០ពិន្ទុ) | ៥.៤.១ ការប្រើប្រាស់ទឹកស្អាត (១០ពិន្ទុ) | | | | | | |
| | | ➢ មានទឹកស្អាតប្រើប្រាស់នៅក្នុងសាលារៀន | | | | | | |
| | | ➢ ទឹកប្រើប្រាស់ជាទឹកដែលមានគុណភាព និងអនាម័យ | | | | | | |
| | | ៥.៤.២ ការលក់ចំណីអាហារ (១០ពិន្ទុ) | | | | | | |
| | | ➢ ទីតាំងលក់ចំណីអាហារមិនរំខានដល់ការសិក្សា មានអនាម័យ និងបរិស្ថានស្អាត | | | | | | |
| | | ➢ មានកិច្ចសន្យាជាមួយអ្នកលក់ដូរ មានការត្រួតពិនិត្យ និងផ្តល់ការណែនាំជាប្រចាំអំពីគុណភាពចំណីអាហារ | | | | | | |
| **៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ** (៧០ពិន្ទុ) | ៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ (៥៥ពិន្ទុ) | ៦.១.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ (២៥ពិន្ទុ) | | | | | | |
| | | ➢ ការផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ (ការផ្សារភ្ជាប់សាលារៀននិងសហគមន៍) | | | | | | |
| | | ➢ កម្មវិធីដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍ | | | | | | |
| | | ➢ ការជំរុញការបង្កើត ការរក្សា និងការតាំងបង្ហាញស្នាដៃសិស្ស | | | | | | |
| | | ➢ ការចូលរួមវាយតម្លៃពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ | | | | | | |
| | | ➢ កម្រិតនៃការពេញចិត្តរបស់អ្នកប្រើសេវា និងសហគមន៍ចំពោះគុណភាពសេវារបស់សាលារៀន | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ៦.១.២ ការកៀរគរធនធាន និងការសហការជាមួយដៃគូអភិវឌ្ឍ (១០ពិន្ទុ) | | | | | | |
| | | ➢ ការបង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន | | | | | | |
| | | ➢ ការសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន | | | | | | |
| | | ៦.១.៣ ទំនាក់ទំនងជាមួយនឹងអាជ្ញាធរ (២០ពិន្ទុ) | | | | | | |
| | | ➢ ការសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការអប់រំនិងទប់ស្កាត់ និងដោះស្រាយបញ្ហាគ្រឿងញៀន គ្រឿងស្រវឹង និងបទល្មើសផ្សេងៗ | | | | | | |
| | | ➢ ការសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការអប់រំនិងទប់ស្កាត់ និងដោះស្រាយសុវត្ថិភាពចរាចរណ៍ | | | | | | |
| | | ➢ ការសហការជាមួយអាជ្ញាធរដែនដីក្នុងការទប់ស្កាត់ និងដោះស្រាយបញ្ហាក្មេងទំនើង និងសិស្សគេចសាលា | | | | | | |
| | | ➢ ការកៀរគរការគាំទ្ររបស់អាជ្ញាធរក្នុងការអភិវឌ្ឍសាលារៀន | | | | | | |
| | ៦.២ ការអភិវឌ្ឍកុមារ/យុវជន (១៥ពិន្ទុ) | ៦.២.១ ការងារអភិវឌ្ឍកុមារ/យុវជន (១៥ពិន្ទុ) | | | | | | |
| | | ➢ រចនាសម្ព័ន្ធ និងកិច្ចដំណើរការក្រុមប្រឹក្សាកុមារ/យុវជន | | | | | | |
| | | ➢ បណ្ដុះបណ្ដាលនិងអប់រំភាពជាអ្នកដឹកនាំ សហគ្រិនភាព និងបំណិនជីវិតដល់កុមារនិងយុវជន | | | | | | |
| | | ➢ ក្លឹបសិក្សា/បន្ទប់ប្រឹក្សាអាជីព/កងកាយរឹទ្ធិ/កាកបាទក្រហម | | | | | | |
| **៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍** (២៥ពិន្ទុ) | ៧.១ យន្តការទទួលព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ា (១០ពិន្ទុ) | ៧.១.១ យន្តការទទួលព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ា (១០ពិន្ទុ) | | | | | | |
| | | ➢ បានរៀបចំនិងដំណើរការយន្តការទទួលព័ត៌មានត្រឡប់និងបណ្ដឹងតវ៉ាអំពីសេវារបស់សាលារៀន | | | | | | |
| | | ➢ ឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្ដឹងតវ៉ា តាមពេលវេលាសមស្រប និងតាមករណីនីមួយៗ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៧.២ ការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ស្របតាមស្ថានភាពជាក់ស្តែង (១៥ពិន្ទុ) | ៧.២.១ កិច្ចសហការជាមួយមាតាបិតា អ្នកអាណាព្យាបាល និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយបញ្ហាប្រឈម (១៥ពិន្ទុ) | | | | | | |
| | | ➢ មានការប្រជុំក្រុមប្រឹក្សាភិបាល(ក.ប.ស)/គណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)/គណៈកម្មការទ្រទ្រង់សាលារៀន(គ.ទ.ស) | | | | | | |
| | | ➢ មានការកែលម្អការផ្តល់សេវាផ្អែកលើព័ត៌មានត្រឡប់របស់អ្នកប្រើសេវា សហគមន៍ និងអាជ្ញាធរដែនដី | | | | | | |
| | | ➢ មានការគាំទ្រ និងជំរុញដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សជួយសិស្សរៀនយឺត និងសិស្សរៀនពូកែ/សិស្សដែលមានបញ្ញាខ្ពស់ | | | | | | |
| ៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ (៤៥ពិន្ទុ) | ៨.១ ការបញ្ជ្រាបការយល់ដឹង និងការបំផុសគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាពផ្តល់សេវា (៣៥ពិន្ទុ) | ៨.១.១ ការបញ្ជ្រាបការយល់ដឹងពីនវានុវត្តន៍និងការច្នៃប្រឌិតដល់បុគ្គលិកអប់រំរបស់សាលារៀន (៥ពិន្ទុ) | | | | | | |
| | | ➢ មានការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ឬការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍និងការច្នៃប្រឌិតដល់មន្ត្រីក្នុងអង្គភាព | | | | | | |
| | | ៨.១.២ ការផ្តួចផ្តើមនិងអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងនិងការផ្តល់សេវារបស់សាលារៀន (៣០ពិន្ទុ) | | | | | | |
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការផ្តល់សេវារដ្ឋបាលរបស់សាលារៀន | | | | | | |
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការបង្រៀននិងរៀន | | | | | | |
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការកៀរគរធនធានសម្រាប់គាំទ្រដល់ដំណើរការនិងការអភិវឌ្ឍសាលារៀន | | | | | | |
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុដែលទទួលបានពីសហគមន៍និងសប្បុរសជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព | | | | | | |
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការរៀបចំនិងកែលម្អបរិស្ថានអង្គភាព | | | | | | |
| | ៨.២. ការធ្វើឱ្យមាននិរន្តរភាពការអនុវត្តគំនិតនវានុវត្តន៍ដែលទទួលបានជោគជ័យ និងចែករំលែកជាមួយអង្គភាពដទៃ (១០ពិន្ទុ) | ៨.២.១ ការគាំទ្រនិងការលើកទឹកចិត្តចំពោះគំនិតនវានុវត្តន៍និងការច្នៃប្រឌិត (៥ពិន្ទុ) | | | | | | |
| | | ➢ បានកំណត់គោលការណ៍និងអនុវត្តការគាំទ្រនិងលើកទឹកចិត្តចំពោះការផ្តួចផ្តើមនិងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាព | | | | | | |
| | | ៨.២.២ ការចងក្រង និងចែករំលែកគំនិតនវានុវត្តន៍និងការច្នៃប្រឌិតរបស់អង្គភាព (៥ពិន្ទុ) | | | | | | |
| | | ➢ បានចងក្រងនិងផ្សព្វផ្សាយឬចែករំលែកគំនិតនវានុវត្តន៍និងការច្នៃប្រឌិតដែលបានអនុវត្តនិងទទួលបានលទ្ធផលល្អដល់អង្គភាពផ្តល់សេវាដទៃ | | | | | | |

## ឧបសម្ព័ន្ធទី១នៃប្រកាសអន្តរក្រសួងលេខ ៣៨៤/២៤ មស.គវឌ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យដំណើរការ ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

## តារាងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនិងការទទួលស្គាល់សាលាមត្តេយ្យសិក្សាគំរូ

**(ពិន្ទុសរុប ៦១៥)**

| លក្ខណៈវិនិច្ឆ័យគោល | លក្ខណៈវិនិច្ឆ័យរង | ចំណុចលម្អិត | ពិន្ទុ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ០ | ១ | ២ | ៣ | ៤ | ៥ |
| ១. ស្តង់ដាសេវាសាធារណៈ (៩៥ពិន្ទុ) | ១.១ គុណភាពព័ត៌មាន (២៥ពិន្ទុ) | ១.១.១ បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ មានរក្សាទុកបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់អ្នកប្រើសេវាអាចពិនិត្យផ្ទៀងផ្ទាត់អំពីសេវា | | | | | | |
| | | ➢ បានរៀបចំស្តង់ដាផ្តល់សេវារដ្ឋបាល និងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន | | | | | | |
| | | ១.១.២ ការផ្សព្វផ្សាយព័ត៌មានអំពីសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ បានផ្សព្វផ្សាយផែនការអភិវឌ្ឍរបស់សាលារៀន | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានអំពីប្រភេទសេវា ឯកសារតម្រូវ លក្ខខណ្ឌក្នុងការទទួលសេវា ម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ និងមធ្យោបាយទំនាក់ទំនងរបស់សាលារៀន | | | | | | |
| | | ១.១.៣ មធ្យោបាយផ្សព្វផ្សាយព័ត៌មានអំពីសេវា (៥ពិន្ទុ) | | | | | | |
| | | ➢ បានផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធមិនមែនអេឡិចត្រូនិក និងប្រព័ន្ធអេឡិចត្រូនិក | | | | | | |
| | ១.២ ភាពងាយស្រួលក្នុងការទទួលយកសេវា (២៥ពិន្ទុ) | ១.២.១ ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ (១០ពិន្ទុ) | | | | | | |
| | | ➢ មានហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសាលារៀនប្រកបដោយភាពងាយស្រួលក្នុងការស្វែងរកនិងទទួលយកសេវា | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានបិទបង្ហាញប្លង់ទីតាំងសាលារៀន និងស្លាកសញ្ញាប្រាប់ពីឈ្មោះអង្គភាពទទួលបន្ទុកការងារនីមួយៗច្បាស់លាស់ | | | | | | |
| | | ១.២.២ ទីតាំងផ្តល់សេវា(ថ្នាក់រៀន)ប្រកបដោយផាសុកភាព (៥ពិន្ទុ) | | | | | | |
| | | ➢ ថ្នាក់រៀនមានផាសុកភាព | | | | | | |
| | | ១.២.៣ បែបបទនិងលក្ខខណ្ឌនៃការទទួលយកសេវា (១០ពិន្ទុ) | | | | | | |
| | | ➢ បានសិក្សានិងរៀបចំឯកសារតម្រូវសម្រាប់ទទួលសេវាមានចំនួនតិច និងទម្រង់នៃពាក្យស្នើសុំសេវាមានលក្ខណៈងាយយល់និងងាយបំពេញ | | | | | | |
| | | ➢ នីតិវិធីនៃការទទួលយកសេវាមានលក្ខណៈសាមញ្ញ និងឆាប់រហ័ស | | | | | | |
| | ១.៣ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា (៣០ពិន្ទុ) | ១.៣.១ ការរៀបចំបដិសណ្ឋារកិច្ច (២០ពិន្ទុ) | | | | | | |
| | | ➢ បានរៀបចំឱ្យបុគ្គលិកអប់រំមានឯកសណ្ឋានឬសម្លៀកបំពាក់សមរម្យ និងពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារ | | | | | | |
| | | ➢ បានរៀបចំឱ្យកុមារមានឯកសណ្ឋាន(សម្លៀកបំពាក់សមរម្យ និងមានស្លាកឈ្មោះឬបណ្ណសម្គាល់ខ្លួនជាប្រចាំក្នុងសាលារៀន) | | | | | | |
| | | ➢ ការរៀបចំឱ្យមានទីកន្លែង(ផ្នែក តុ ឬទីតាំង)សម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវារបស់សាលារៀន | | | | | | |
| | | ➢ បុគ្គលិកអប់រំមានភាពរួសរាយរាក់ទាក់ និងមានសីលធម៌/សុជីវធម៌ | | | | | | |
| | | ១.៣.២ យន្តការសម្របសម្រួល (១០ពិន្ទុ) | | | | | | |
| | | ➢ មានការរៀបចំសណ្តាប់ធ្នាប់និងប្រព័ន្ធសុវត្ថិភាពសម្រាប់ការទទួលកុមារចូលនិងចេញពីសាលារៀន និងនៅក្នុងបរិវេណសាលារៀន | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានការយកចិត្តទុកដាក់ចំពោះអ្នកប្រើសេវាមិនមែនជាកុមារ តាមរយៈការផ្តល់ព័ត៌មាននិងសម្រួលការលំបាករបស់អ្នកប្រើសេវា | | | | | | |
| | ១.៤ ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ (១៥ពិន្ទុ) | ១.៤.១ ការផ្តល់សេវាតាមគោលការណ៍កំណត់ (១០ពិន្ទុ) | | | | | | |
| | | ➢ បានផ្តល់សេវាស្របតាមការកំណត់ (ដូចជាតម្លៃ រយៈពេល...) | | | | | | |
| | | ➢ សាលារៀនទទួលបានវិញ្ញាបនបត្រ/បណ្ណសរសើរ/លិខិតសរសើរពីការផ្តល់សេវា(ដៃគូអភិវឌ្ឍ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ថ្នាក់ជាតិ និង/ឬ អន្តរជាតិ) | | | | | | |
| | | ១.៤.២ ការផ្តល់សេវាមានអភិបាលកិច្ចល្អ (៥ពិន្ទុ) | | | | | | |
| | | ➢ បានផ្តល់សេវាប្រកបដោយសមធម៌ និងបរិយាបន្ន (ជួយដល់កុមារដែលមានពិការភាព និងកុមារក្រីក្រ ដោយមានជម្រាលបន្ទប់ស្នាក់នៅ ឧបករណ៍សម្ភារៈជំនួយកុមារដែលមានពិការភាព និងអាហារូបករណ៍...) | | | | | | |
| ២. ស្តង់ដារឬនិយាមនៃការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ (២១០ពិន្ទុ) | ២.១ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន (១៤០ពិន្ទុ) | ២.១.១ ភាពជាអ្នកដឹកនាំសាលារៀន (២៥ពិន្ទុ) | | | | | | |
| | | ➢ មានចក្ខុវិស័យសាលារៀនឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ/គោលនយោបាយអប់រំ | | | | | | |
| | | ➢ មានបេសកកម្មឆ្លើយតបទៅចក្ខុវិស័យ | | | | | | |
| | | ➢ គុណតម្លៃឬបាវចនារបស់សាលារៀន | | | | | | |
| | | ➢ ការរៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកអប់រំបានស្របតាមកម្រិតវិជ្ជាជីវៈ និងនិយាម | | | | | | |
| | | ➢ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការគ្រប់គ្រងសាលារៀន | | | | | | |
| | | ២.១.២ ការរៀបចំផែនការ និងដំណើរការសាលារៀន (២៥ពិន្ទុ) | | | | | | |
| | | ➢ មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន(៥ឆ្នាំ) | | | | | | |
| | | ➢ មានផែនការប្រតិបត្តិប្រចាំឆ្នាំ ឬផែនការកែលម្អសាលារៀន | | | | | | |
| | | ➢ មានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារជាប្រចាំ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ ស្វ័យវាយតម្លៃសាលារៀនប្រចាំឆ្នាំ ឆ្លុះបញ្ចាំងទៅនឹងផែនការប្រចាំឆ្នាំ | | | | | | |
| | | ➢ សមិទ្ធកម្មធៀបនឹងផែនការដែលបានកំណត់ | | | | | | |
| | | ២.១.៣ ការដឹកនាំការបង្រៀននិងរៀន (៤៥ពិន្ទុ) | | | | | | |
| | | ➢ អនុវត្តកម្មវិធីសិក្សាតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា | | | | | | |
| | | ➢ មានការរៀនចំការបង្រៀននិងរៀនទាំងក្នុងថ្នាក់រៀនទាំងក្រៅថ្នាក់រៀន | | | | | | |
| | | ➢ មានរបបប្រជុំក្រុមបច្ចេកទេសតាមកម្រិតថ្នាក់( យ៉ាងតិច ៧ដងក្នុង១ឆ្នាំ ) និងមានរបៀបវារៈច្បាស់លាស់តាមការណែនាំ/ការកំណត់ | | | | | | |
| | | ➢ មានផែនការ និងអនុវត្តអធិការកិច្ចផ្ទៃក្នុងលើការបង្រៀន និងរៀនជាប្រចាំ | | | | | | |
| | | ➢ មានការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សជាប្រចាំ( ការធ្វើតេស្តស្តង់ដា ) | | | | | | |
| | | ➢ មានការផ្តល់និងទទួលព័ត៌មានត្រឡប់អំពីលទ្ធផលសិក្សារបស់សិស្ស( សៀវភៅតាមដានការសិក្សា តាមលិខិតអញ្ជើញ... ) ជាមួយមាតាបិតា ឬអាណាព្យាបាលសិស្ស សហគមន៍ និងអ្នកពាក់ព័ន្ធជាប្រចាំ | | | | | | |
| | | ➢ រៀបចំឱ្យមានសម្ភារៈសិក្សា និងសម្ភារៈឧបទេសតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ | | | | | | |
| | | ➢ រៀបចំឱ្យមានសម្ភារៈល្បែងសិក្សា | | | | | | |
| | | ➢ មានការរៀបចំកិច្ចតែងការបង្រៀន | | | | | | |
| | | ២.១.៤ ការជានាគណនេយ្យភាព (១០ពិន្ទុ) | | | | | | |
| | | ➢ ការគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធរាយការណ៍ | | | | | | |
| | | ➢ បិទផ្សាយលទ្ធផលសិក្សារបស់សិស្សដោយតម្លាភាព | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២.១.៥ ការគ្រប់គ្រងប្រកបដោយសុចរិតភាព (១៥ពិន្ទុ) | | | | | | |
| | | ➢ ការណែនាំនិងផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | | | | | | |
| | | ➢ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | | | | | | |
| | | ➢ ផ្តល់ដំបូន្មាន និងអប់រំណែនាំអំពីបទបញ្ជាផ្ទៃក្នុង វិន័យសាលា និងសុជីវធម៌ដល់សិស្សជាប្រចាំ | | | | | | |
| | | ២.១.៦ លទ្ធផលនៃការសិក្សា (២០ពិន្ទុ) | | | | | | |
| | | ➢ អត្រាកុមារអាយុ៣ឆ្នាំចុះឈ្មោះចូលរៀនធៀបនឹងឆ្នាំចាស់ | | | | | | |
| | | ➢ អត្រាកុមារអាយុ៤ឆ្នាំចុះឈ្មោះចូលរៀនធៀបនឹងឆ្នាំចាស់ | | | | | | |
| | | ➢ អត្រាកុមារអាយុ៥ឆ្នាំចុះឈ្មោះចូលរៀនធៀបនឹងឆ្នាំចាស់ | | | | | | |
| | | ➢ កុមារមានសមត្ថភាពស្របតាមកម្រិតថ្នាក់ | | | | | | |
| | ២.២ សេវាធានាឱ្យមានគុណភាព សមធម៌ និងបរិយាបន្ននៅក្នុងសាលារៀន (៣០ពិន្ទុ) | ២.២.១ សកម្មភាពធានាដល់ការបង្រៀននិងរៀនប្រកបដោយគុណភាព (៣០ពិន្ទុ) | | | | | | |
| | | ➢ មានការពិនិត្យសុខភាពកុមារជាប្រចាំ | | | | | | |
| | | ➢ ជំរុញការចាក់ថ្នាំបង្ការជាប្រចាំ | | | | | | |
| | | ➢ មានការផ្តល់អាហារតាមកម្មវិធីអាហារូបត្ថម្ភ | | | | | | |
| | | ➢ មានកន្លែងសម្រាប់កុមារញ៉ាំអាហារប្រកបដោយអនាម័យ | | | | | | |
| | | ➢ មានទីធ្លាសម្រាប់អប់រំកាយនិងកីឡា | | | | | | |
| | | ➢ មានកន្លែងសម្រាកនិងការសម្រាកពេលថ្ងៃប្រកបផាសុកភាព | | | | | | |
| | ២.៣ គុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈបុគ្គលិកអប់រំ (៤០ពិន្ទុ) | ២.៣.១ ចំណេះដឹង និងសមត្ថភាពជំនាញរបស់បុគ្គលិកអប់រំ (៣០ពិន្ទុ) | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំមានគុណវុឌ្ឍិចាប់ពីបរិញ្ញាបត្រឡើងទៅ | | | | | | |
| | | ➢ ភាគរយនៃបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតបឋមសិក្សា | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំមានសញ្ញាបត្រគ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ ភាគរយនៃការប្រើប្រាស់កម្មវិធីសិក្សាតាមកម្រិតថ្នាក់របស់បុគ្គលិកអប់រំ | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំមានចំណេះដឹង និងប្រើបច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស បម្រើឱ្យការងាររដ្ឋបាល និងការងារបច្ចេកទេស | | | | | | |
| | | ➢ ភាគរយបុគ្គលិកអប់រំដែលបានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ | | | | | | |
| | | ២.៣.២ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់គ្រូបង្រៀន (១០ពិន្ទុ) | | | | | | |
| | | ➢ មានសៀវភៅរដ្ឋបាលថ្នាក់រៀន | | | | | | |
| | | ➢ មានការតាមដាន និងវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ | | | | | | |
| **៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព** (៩៥ពិន្ទុ) | ៣.១ ភាពជឿទុកចិត្តនៃថវិកា (៣៥ពិន្ទុ) | ៣.១.១ ការរៀបចំផែនការថវិកា (១០ពិន្ទុ) | | | | | | |
| | | ➢ ផែនការយុទ្ធសាស្ត្រថវិកា(៣ឆ្នាំ) រំកិល (Y+1, Y+2, Y+3) | | | | | | |
| | | ➢ ផែនការថវិកាប្រចាំឆ្នាំ (Y+1) | | | | | | |
| | | ៣.១.២ ការអនុវត្តថវិកា (១០ពិន្ទុ) | | | | | | |
| | | ➢ ការអនុវត្តថវិកាស្របតាមការគ្រោងទុក | | | | | | |
| | | ➢ ការរៀបចំតារាងតម្លាភាពថវិកា និងគណនេយ្យភាពថវិកាឱ្យទៀងទាត់និងទាន់ពេល | | | | | | |
| | | ៣.១.៣ ការកៀរគរថវិកា/គ្រប់គ្រងថវិកាប្រកដោយតម្លាភាពនិងគណនេយ្យភាពសម្រាប់អភិវឌ្ឍសាលារៀន (១៥ពិន្ទុ) | | | | | | |
| | | ➢ ការរៀបចំសមាសភាពនិងមុខងារគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈស្របតាមគោលការណ៍កំណត់ | | | | | | |
| | | ➢ ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនប្រកបដោយគណនេយ្យភាព និងប្រសិទ្ធភាព | | | | | | |
| | | ➢ ការកៀរគរថវិកាពីប្រភពស្របច្បាប់ផ្សេងៗដើម្បីអភិវឌ្ឍសាលារៀន | | | | | | |
| | ៣.២ ប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ (៣៥ពិន្ទុ) | ៣.២.១ ដំណើរការនៃការកត់ត្រា (២០ពិន្ទុ) | | | | | | |
| | | ➢ មានបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារកត់ត្រាគ្រប់ប្រតិបត្តិការ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | សាច់ប្រាក់ក្នុងគណនីធនាគាររបស់សាលារៀនជាប្រចាំ(គំរូលេខ២៤) | | | | | | |
| | | ➢ មានបញ្ជីបេឡាសម្រាប់តាមដានស្ថានភាពចំណូលចំណាយ និង ចំនួនសាច់ប្រាក់ ដែលនៅសល់ចុងថ្ងៃ និងចុងខែ (គំរូលេខ២៥) | | | | | | |
| | | ➢ កត់ត្រាកិច្ចបញ្ជិកាគណនេយ្យតាមកុំព្យូទ័រដោយប្រើ Ms.Excel ឬ កម្មវិធីដទៃទៀត | | | | | | |
| | | ➢ ការគ្រប់គ្រងឯកសារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ត្រូវបានរក្សាទុកតាមក្រូណូ តាមលំដាប់ និងមានភាពងាយស្រួលសម្រាប់ការប្រើប្រាស់ | | | | | | |
| | | ៣.២.២ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (១៥ពិន្ទុ) | | | | | | |
| | | ➢ ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋឱ្យបានទៀងទាត់និងជាប្រចាំ | | | | | | |
| | | ➢ ការធ្វើបច្ចុប្បន្នកម្មតារាងប្រៀបធៀប(កើន/ថយចុះ) ទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវ | | | | | | |
| | | ➢ ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លី ឬ/និង អចលនទ្រព្យរបស់សាលារៀន | | | | | | |
| | ៣.៣ ការតាមដាន និងការត្រួតពិនិត្យ (២៥ពិន្ទុ) | ៣.៣.១ ប្រព័ន្ធរបាយការណ៍តាមដានជាប្រចាំ (២៥ពិន្ទុ) | | | | | | |
| | | ➢ មានរបាយការណ៍ចំណាយថវិកាប្រចាំខែ(ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំខែ និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល) | | | | | | |
| | | ➢ មានរបាយការណ៍ចំណាយថវិកាប្រចាំត្រីមាស(ជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំត្រីមាស និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល) | | | | | | |
| | | ➢ មានរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសដែលឆ្លុះបញ្ចាំងពីព័ត៌មានសមិទ្ធកម្មគ្រប់ជ្រុងជ្រោយ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សាលារៀន និងរបាយការណ៍ | | | | | | |
| | | ➢ កាអនុវត្តតាមអនុសាសន៍ចុងក្រោយរបស់សវនកម្មផ្ទៃក្នុង ឬ អធិការកិច្ច | | | | | | |
| **៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព** (៥៥ពិន្ទុ) | ៤.១ ការគ្រប់គ្រងធនធានមនុស្ស (៤០ពិន្ទុ) | ៤.១.១ ការរៀបចំនិងអនុវត្តផែនការគ្រប់គ្រងធនធានមនុស្ស (៥ពិន្ទុ) | | | | | | |
| | | ➢ មានផែនការគ្រប់គ្រងធនធានមនុស្ស | | | | | | |
| | | ៤.១.២ ការគ្រប់គ្រងការវិវត្តន៍អាជីពរបស់បុគ្គលិកអប់រំ (១០ពិន្ទុ) | | | | | | |
| | | ➢ ការដំឡើងថ្នាក់និងឋានន្តរស័ក្តិត្រូវបានរៀបចំជាទៀងទាត់ | | | | | | |
| | | ➢ ការរៀបចំដាក់ឱ្យចូលនិវត្តន៍គោរពតាមគោលការណ៍កំណត់ | | | | | | |
| | | ៤.១.៣ ការគ្រប់គ្រងសមិទ្ធកម្ម (២៥ពិន្ទុ) | | | | | | |
| | | ➢ ការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាព | | | | | | |
| | | ➢ ការរៀបចំការពិពណ៌នាមុខតំណែងឬការបែងចែកការកិច្ចសម្រាប់មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ (គណៈគ្រប់គ្រង ក្រុមបច្ចេកទេស គ្រូបង្រៀន និងបុគ្គលិកអប់រំ...) | | | | | | |
| | | ➢ ការគ្រប់គ្រងវត្តមានការបំពេញការងាររបស់បុគ្គលិកអប់រំជាទៀងទាត់ | | | | | | |
| | | ➢ មានការវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្ត | | | | | | |
| | | ➢ មានការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងអង្គភាព | | | | | | |
| | ៤.២ ការអភិវឌ្ឍធនធានមនុស្ស (១៥ពិន្ទុ) | ៤.២.១ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស (៥ពិន្ទុ) | | | | | | |
| | | ➢ មានការរៀបចំផែនការសិក្សាវិជ្ជាជីវៈ និងការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (ចូលរួមសិក្សារៀនសូត្រដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង ជំនាញ និងការអនុវត្តការងារឆ្លើយតបទៅនឹងតម្រូវការវិជ្ជាជីវៈ តម្រូវការរបស់សាលារៀន និងកំណែទម្រង់វិស័យអប់រំ) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ៤.២.២ ការអភិវឌ្ឍនិងការប្រើធនធានមនុស្សដែលទទួលបានការបណ្ដុះបណ្ដាល(១០ពិន្ទុ) | | | | | | |
| | | ➢ លើកទឹកចិត្តនិងប្រើប្រាស់វិធីសាស្ត្រផ្សេងៗដើម្បីឱ្យមន្ត្រីទទួលបានការបណ្ដុះបណ្ដាល | | | | | | |
| | | ➢ មានការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំជាបន្តបន្ទាប់ | | | | | | |
| **៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព** (៨០ពិន្ទុ) | ៥.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត សុខភាព និងអនាម័យ (១៥ពិន្ទុ) | ៥.១.១ ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន ភាពស្អាត សុខភាព និងអនាម័យ (១៥ពិន្ទុ) | | | | | | |
| | | ➢ បានបញ្ចូលផែនការបរិស្ថាន ភាពស្អាត សុខភាព និងអនាម័យ ទៅក្នុងផែនការអភិវឌ្ឍសាលារៀន/កែលម្អសាលារៀន(តារាងផែនការប្រចាំឆ្នាំ) | | | | | | |
| | | ➢ មានការអប់រំអំពីការទុកដាក់សំរាម ជាពិសេសគោលការណ៍4R និងការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ដល់បុគ្គលិកអប់រំនិងកុមារទាំងអស់នៅក្នុងសាលារៀន | | | | | | |
| | | ➢ មានការអប់រំសុខភាពនិងអនាម័យដល់មាតាបិតា អ្នកអាណាព្យាបាល និងកុមារ | | | | | | |
| | ៥.២ សោភ័ណភាពបរិស្ថានសាលារៀន (៣៥ពិន្ទុ) | ៥.២.១ ការអនុវត្តដើម្បីសុខភាព អនាម័យ ភាពស្អាត និងបៃតង នៅក្នុងសាលារៀន (៣៥ពិន្ទុ) | | | | | | |
| | | ➢ ទីធ្លាសាលារៀនមានភាពបៃតង សោភ័ណភាព សុវត្ថិភាព សណ្ដាប់ធ្នាប់ និងអនាម័យ | | | | | | |
| | | ➢ បន្ទប់រៀនមានសោភ័ណភាព និងមានការសម្អាតជាប្រចាំ | | | | | | |
| | | ➢ គ្មានការបំពុលបរិស្ថាន(ផ្សែង សំឡេង ក្លិន...) និងគ្មានផ្សែងបារីនៅក្នុងបរិវេណសាលារៀន | | | | | | |
| | | ➢ មានប្រអប់សង្គ្រោះបឋម និងបរិក្ខារជំនួយ | | | | | | |
| | | ➢ មានការបែងចែកបង្គន់សម្រាប់កុមារានិងកុមារី និងបុគ្គលិកអប់រំ | | | | | | |
| | | ➢ បង្គន់ប្រកបដោយភាពស្អាត សុវត្ថិភាព អនាម័យ និងសោភ័ណភាព | | | | | | |
| | | ➢ មានកន្លែងលាងសម្អាតដៃប្រកបដោយសុវត្ថិភាព សណ្ដាប់ធ្នាប់ អនាម័យ និងសោភ័ណភាព | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៥.៣ ទីតាំងលេងកំសាន្ត និងគ្រប់គ្រងកាកសំណល់ (២០ពិន្ទុ) | ៥.៣.១ ទីលានលេងកំសាន្ត និង អប់រំកាយនិងកីឡា (៥ពិន្ទុ) | | | | | | |
| | | ➢ មានសួនកុមារ ឬកន្លែងលេងកម្សាន្តប្រកបដោយសុវត្ថិភាពនិងអនាម័យ | | | | | | |
| | | ៥.៣.២ ការគ្រប់គ្រងកាកសំណល់(ប្លាស្ទិក) និងប្រព័ន្ធលូ (១៥ពិន្ទុ) | | | | | | |
| | | ➢ មានធុងសំរាមនិងបានញែកសំរាម(ជាពិសេសសំរាមប្លាស្ទិក) ព្រមទាំងមានការសម្អាតជាប្រចាំ | | | | | | |
| | | ➢ មានទីតាំងសម្រាប់ស្តុកសំរាមប្រកបដោយសណ្តាប់ធ្នាប់ អនាម័យ និងសុវត្ថិភាព | | | | | | |
| | | ➢ មានប្រព័ន្ធគ្រប់គ្រងសំណល់រាវ និងមានការថែទាំជាប្រចាំ (ប្រព័ន្ធលូរំដោះទឹក និងទឹកសំអុយ) | | | | | | |
| | ៥.៤ ការប្រើប្រាស់ទឹកស្អាត និងអនាម័យក្នុងបរិវេណសាលារៀន (១០ពិន្ទុ) | ៥.៤.១ ការប្រើប្រាស់ទឹកស្អាត (១០ពិន្ទុ) | | | | | | |
| | | ➢ មានទឹកស្អាតប្រើប្រាស់នៅក្នុងសាលារៀន | | | | | | |
| | | ➢ ទឹកប្រើប្រាស់ជាទឹកដែលមានគុណភាព និងអនាម័យ | | | | | | |
| ៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ (៤០ពិន្ទុ) | ៦.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរ និងដៃគូអភិវឌ្ឍ (៤០ពិន្ទុ) | ៦.១.១ ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ (១៥ពិន្ទុ) | | | | | | |
| | | ➢ ការជំរុញការបង្កើត ការរក្សា និងការតាំងបង្ហាញស្នាដៃសិស្ស | | | | | | |
| | | ➢ ការចូលរួមវាយតម្លៃពីមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធ | | | | | | |
| | | ➢ កម្រិតនៃការពេញចិត្តរបស់អ្នកប្រើសេវា និងសហគមន៍ចំពោះគុណភាពសេវារបស់សាលារៀន | | | | | | |
| | | ៦.១.២ ការកៀរគរធនធាន និងការសហការជាមួយដៃគូអភិវឌ្ឍ (១០ពិន្ទុ) | | | | | | |
| | | ➢ ការបង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន | | | | | | |
| | | ➢ ការសហការជាមួយដៃគូអភិវឌ្ឍ ជាអង្គការជាតិ អន្តរជាតិ និងសប្បុរសជន | | | | | | |
| | | ៦.១.៣ ទំនាក់ទំនងជាមួយនឹងអាជ្ញាធរ (១៥ពិន្ទុ) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ ការសហការជាមួយ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការទប់ស្កាត់បញ្ហាក្មេងទំនើង និងបទល្មើសផ្សេងៗចូលក្នុងសាលារៀន | | | | | | |
| | | ➢ ការសហការ និងកៀរគរការគាំទ្រពីអាជ្ញាធរដែនដីក្នុងការអប់រំនិងទប់ស្កាត់ និងដោះស្រាយសុវត្ថិភាពចរាចរណ៍ | | | | | | |
| | | ➢ ការកៀរគរការគាំទ្ររបស់អាជ្ញាធរក្នុងការអភិវឌ្ឍសាលារៀន | | | | | | |
| **៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍** (២០ពិន្ទុ) | ៧.១ យន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា (១០ពិន្ទុ) | ៧.១.១ យន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា(១០ពិន្ទុ) | | | | | | |
| | | ➢ បានរៀបចំនិងដំណើរការយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ាអំពីសេវារបស់សាលារៀន | | | | | | |
| | | ➢ ឆ្លើយតបទៅនឹងព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា តាមពេលវេលាសមស្រប និងតាមករណីនីមួយៗ | | | | | | |
| | ៧.២ ការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ស្របតាមស្ថានភាពជាក់ស្តែង (១០ពិន្ទុ) | ៧.២.១ កិច្ចសហការជាមួយមាតាបិតា អ្នកអាណាព្យាបាល និងអាជ្ញាធរដែនដី ដើម្បីដោះស្រាយបញ្ហាប្រឈម (១០ពិន្ទុ) | | | | | | |
| | | ➢ មានការប្រជុំក្រុមប្រឹក្សាភិបាល(ក.ប.ស)/គណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)/គណៈកម្មការទ្រទ្រង់សាលារៀន(គ.ទ.ស) | | | | | | |
| | | ➢ មានការកែលម្អការផ្តល់សេវាផ្អែកលើព័ត៌មានត្រឡប់របស់អ្នកប្រើសេវា សហគមន៍ និងអាជ្ញាធរដែនដី | | | | | | |
| **៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ** (២០ពិន្ទុ) | ៨.១ ការបញ្ជ្រាបការយល់ដឹង និងការបំផុសគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាពផ្តល់សេវា (១០ពិន្ទុ) | ៨.១.១ ការបញ្ជ្រាបការយល់ដឹងពីនវានុវត្តន៍និងការច្នៃប្រឌិតដល់បុគ្គលិកអប់រំរបស់សាលារៀន (៥ពិន្ទុ) | | | | | | |
| | | ➢ មានការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ឬការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងនវានុវត្តន៍និងការច្នៃប្រឌិតដល់មន្ត្រីក្នុងអង្គភាព | | | | | | |
| | | ៨.១.២ ការផ្តួចផ្តើមនិងអនុវត្តនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការគ្រប់គ្រងនិងការផ្តល់សេវារបស់សាលារៀន (៥ពិន្ទុ) | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ➢ មានការផ្តួចផ្តើមនិងអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងការផ្តល់សេវារដ្ឋបាលរបស់សាលារៀន | | | | | | |
| | ៨.២. ការធ្វើឱ្យមាននិរន្តរភាពការអនុវត្តគំនិតនវានុវត្តន៍ដែលទទួលបានជោគជ័យ និងចែករំលែកជាមួយអង្គភាពដទៃ (១០ពិន្ទុ) | ៨.២.១ ការគាំទ្រនិងការលើកទឹកចិត្តចំពោះគំនិតនវានុវត្តន៍និងការច្នៃប្រឌិត (៥ពិន្ទុ) | | | | | | |
| | | ➢ បានកំណត់គោលការណ៍និងអនុវត្តការគាំទ្រនិងលើកទឹកចិត្តចំពោះការផ្តួចផ្តើមនិងការអនុវត្តគំនិតនវានុវត្តន៍និងការច្នៃប្រឌិតក្នុងអង្គភាព | | | | | | |
| | | ៨.២.២ ការចងក្រង និងចែករំលែកគំនិតនវានុវត្តន៍និងការច្នៃប្រឌិតរបស់អង្គភាព (៥ពិន្ទុ) | | | | | | |
| | | ➢ បានចងក្រងនិងផ្សព្វផ្សាយឬចែករំលែកគំនិតនវានុវត្តន៍និងការច្នៃប្រឌិតដែលបានអនុវត្តនិងទទួលបានលទ្ធផលល្អដល់អង្គភាពផ្តល់សេវាដទៃ | | | | | | |